# ដំណាំស្ពៃខៀវ



ដោយៈអគ្គនាយកដ្ឋានកសិកម្ម

## ១ ការរៀបចំដី

- ត្រូវភ្ជួររាស់ដីហាលចោលពី ៧-១០ថ្ងៃ ភ្ជួរពីជម្រៅពី ១៥-៣០ ស.ម
- ភ្ជួរឲ្យបាន ២-៣ដង ដើម្បីត្រឡប់ស្មៅចូលទៅក្នុងដីទុកឲ្យរលួយទៅជាជី សម្លាប់ពងដង្កូវសម្លាប់សត្វល្អិតដែលមាននៅក្នុងដី ធ្វើឲ្យដីធូរ និងមានខ្យល់ចេញចូលល្អ។



ទិដ្ឋភាពការរៀបចំដី

## ២ ការលើករង

ទទឹងរង ០.៨-១ម៉ែត្រ បណ្តោយ ១០ម៉ែត្រ ឬតាមលទ្ធភាពដីដែលមាន៖

- ចន្លោះពីរងមួយទៅរងមួយ ២៥-៣០ ស.ម
- នៅរដូវវស្សាលើករងកម្ពស់ពី ២០-២៥ ស.ម រាងខ្នងអណ្តើក ឬខ្ពស់ជាងនេះទៅតាមស្ថានភាពដី
- នៅរដូវប្រាំងលើករងកម្ពស់ពី ១០-១៥ ស.ម រាងផតកណ្តាល
- ដាក់ជីធម្មជាតិ ឬកំប៉ុស្តសម្រាប់ទ្រាប់បាតពី១០-១៥គីឡូក្រាម និងជី (១៥.១៥.១៥) ១០០-១៥០ក្រាម លើផ្ទៃដី ១០ម៉ែត្រការ៉េ ច្របល់រួចរាស់ ឬកៀរឲ្យរាបស្មើ។

## ៣ រៀបដាំដុះ

### ៣.១. ការសាបគ្រាប់

- យកគ្រាប់ហាលថ្ងៃរយៈពេល ពី ២០-៣០ នាទី ហើយត្រាំទឹកពី ២ម៉ោង និងផ្អាប់ ១ យប់ដើម្បីគ្រាប់រីក
- គេត្រូវរៀបចំថ្នាលឲ្យបានស្អាតដោយធ្វើដីឲ្យហ្មត់ល្អរួចយកគ្រាប់មកលាយដីខ្សាច់ ៤ភាគ ច្របល់ឲ្យស្មើសាច់ រួចពោយលើថ្នាលឲ្យរង្វើល
- យកផេះបាចជុំវិញថ្នាលដើម្បីការពារសត្វល្អិត និងស្រមោចពាំគ្រាប់ពូជ។

### ៣.២. ការដកស្ទូង

- ការស្ទូងត្រូវធ្វើនៅពេលកូនស្ពៃមានអាយុ



ការសាបកូនដោយគ្រាប់

ពី ១៥-២៥ថ្ងៃ ឬនៅពេលវាមានសន្លឹកពី ៣-៤ សន្លឹក

- ផ្អាកការស្រោចទឹក២ថ្ងៃមុនដក ដើម្បីឲ្យកូនស្ពៃអាចធន់ទ្រាំទៅនឹងកំដៅ
- ត្រូវស្រោចទឹកលើថ្នាលកូនស្ពៃឲ្យបានសើមល្អ ងាយស្រួលក្នុងការដកយកទៅស្ទូង
- ត្រូវដកកូនបន្ទាប់ពីស្រោចទឹកភ្លាម

- ដកយកកូនស្ពៃណា ដែលមានសុខភាពល្អ លូតលាស់ល្អ និងកូនស្ពៃដែលមានទំហំប្រហាក់ប្រហែលគ្នា
- ស្ទូងចន្លោះគុម្ពពី ១៥-២០ ស.ម និងចន្លោះរង ២០-៣០ ស.ម (ជាមធ្យម ១៦-២០ដើមក្នុង១ម៉ែត្រការ៉េ)
- ត្រូវគ្របកូនស្ពៃសន្ទូង២-៣ថ្ងៃ ដើម្បីការពារកំដៅថ្ងៃ។



*ការដាំកូនស្ពៃដោយស្ទូង*

## ៤. ការថែទាំ គ្រប់គ្រងសត្វល្អិត និងជំងឺ

### ៤.១. ការថែទាំ

**ក. ការកំចាត់ស្មៅ និងជ្រួយដី**

- ការសំអាតស្មៅ ធ្វើឡើងដោយដៃ ចបជីក ចបកាប់ និងបន្ទះឬស្សីសម្រាប់ជ្រួយដី វិធីនេះងាយស្រួលក្នុងការអនុវត្តនៅជុំវិញរង និងចន្លោះរង
- ការជំរះស្មៅ និងជ្រួយដី ត្រូវធ្វើឡើងនៅពេលកូនស្ពៃស្ទូងបាន១០ថ្ងៃ ហើយធ្វើដោយប្រុងប្រយ័ត្ន លៃយ៉ាងណា កុំឲ្យប៉ះពាល់ដល់ឫសស្ពៃ ជាហេតុនាំឲ្យអន់ ឬងាប់កូនស្ពៃ។

**ខ. ការស្រោចស្រព**

- ស្រោចទឹក១ថ្ងៃ ២ដង ព្រឹក និងល្ងាច
- នៅរដូវវស្សា បើមានភ្លៀងធ្លាក់ខ្លាំងក៏ដោយ គេត្រូវស្រោចទឹកដើម្បីលាងសំអាតកំទេចកំទីដីដែលជាប់ ឬ នៅបណ្តូលស្ពៃ ដែលជាហេតុធ្វើឲ្យរលួយខូច។
- ប្រសិនបើមានភ្លៀងធ្លាក់ខ្លាំងត្រូវបង្ហូរទឹកចេញពីរង
- ត្រូវបង្កើនបរិមាណទឹកស្រោច ចាប់ពីពេលស្ទូង រហូតដល់ពេលប្រមូលផល។



*ការស្រោចស្រព*

**គ.ការដាក់ជី**

ការដាក់ជីចែកចេញជាបីដំណាក់កាលដូចជាៈ

**ដំណាក់កាលទី១ ៖**

៥-៧ថ្ងៃក្រោយពេលស្ទូងដាក់ជីបំប៉នប្រើជីអ៊ុយរ៉េ ៥-៧ក្រាម លើផ្ទៃដី ១ ម៉ែត្រការ៉េ ឬ១ស្លាបព្រាបាយលាយទឹក ២០លីត្រ រួចស្រោចទឹកលាងតាមក្រោយការពារ កុំឲ្យស្លឹកស្ពៃរលួយ។

**ដំណាក់កាលទី២ ៖**

៥-៧ថ្ងៃក្រោយពេលស្ទូង ប្រើជី (១៥.១៥.១៥) ចំនួន១០-១៥ក្រាម លើផ្ទៃដី ១ម៉ែត្រការ៉េ រោយតាមចន្លោះគុម្ព ហើយស្រោចទឹកឲ្យជោគ។

**ដំណាក់កាលទី៣ ៖**

២០ថ្ងៃក្រោយពេលស្ទូង ដាក់ជីបំប៉នប្រើជីអ៊ុយរ៉េ ១៥-២០ក្រាម លើផ្ទៃដី ១ម៉ែត្រការ៉េ ឬ២ស្លាបព្រាបាយលាយជាមួយទឹក ២០លីត្រ រួចស្រោចទឹកលាងតាមក្រោយឲ្យជោគ។





*ការដាក់ជីទ្រាប់បាត*

**ឃ. ការគ្របប្លាស្ទិក**

ជាទូទៅកសិករមិនសូវមានការដាំដុះដំណាំស្ពៃនៅរដូវវស្សាទេ ពីព្រោះមានភ្លៀងធ្លាក់ច្រើនដែលធ្វើឲ្យ ដំណាំស្ពៃរលួយ និងមិនទទួលបានផល។ ការគ្របប្លាស្ទិកជាវិធីមួយជួយឲ្យការដាំដុះដំណាំស្ពៃទទួលបានជោគជ័យ និងទទួលបានតម្លៃខ្ពស់នៅរដូវវស្សា។

**៤.២. ការគ្រប់គ្រងសត្វល្អិត និងជំងឺ**

**ក. ជំងឺ**

នៅក្នុងដំណាក់កាលលូតលាស់ គេប្រទះឃើញកើតមាននូវជំងឺបាក់តេរី ជំងឺផ្សិត បណ្ដាលមកពីដើមស្ពៃមាន ស្លាកស្នាម ក្រោយពេលសត្វល្អិតបំផ្លាញ ឬស្លឹកនៅផ្នែកខាងក្រោមប៉ះផ្ទាល់នឹងដី។

**វិធានការការពារ និងកំចាត់**

- ហាលដីឲ្យស្ងួតល្អ
- បន្ថយការស្រោចទឹក ពេលពិនិត្យឃើញមានជំងឺកើតឡើង
- ថ្នាំម៉ង់កូហ្សិប(Mancozeb)កម្រិត៤០ក្រាមក្នុងបរិមាណទឹក២០លីត្រ។





*ជំងឺពកឫស*



ជំងឺហ្វុយសារីយ៉ូម (Fusarium Yellow)



ជំងឺរលាកស្លឹក (Alternaria leaf spot)



ជំងឺផ្សិតម្សៅ (Downy Mildew)